UNITED NATIONS
Cambodia Office of the
High Commissioner for Human Rights

NATIONS UNIES
Bureau du Haut Commissaire
aux droits de l'homme au Cambodge

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# ការិយាល័យនៃឧត្តមស្នងការ
# អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

## ករណីឃាតកម្ម និងការស្លាប់ដោយអំពើឃោរឃៅដទៃទៀត ដែលបាន ស្រាវជ្រាវឃើញ នៅក្នុង និងនៅជុំវិញរាជធានីភ្នំពេញ ចន្លោះពីថ្ងៃទី ៧ និងថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៩៨

១- ឈ្មោះ ថែម ពេច ហៅ ហ៊ន កែវដារី អាយុ ៣៨ ឆ្នាំ អ្នករត់ម៉ូតូឌុប រស់នៅក្នុងសង្កាត់ទន្លេបាសាក់ ត្រូវបានសម្លាប់ដោយបាញ់នឹងកាំភ្លើងមួយគ្រាប់ចំក្បាល នៅយប់ថ្ងៃទី ៧ ខែកញ្ញា នៅមុខសណ្ឋាគារខាំបូឌីយ៉ាណា ។ នៅយប់នោះ ឈ្មោះ ថែម ពេច បានចេញពីផ្ទះទៅចូលរួមបាតុកម្មនៅមុខរដ្ឋសភា ហើយបន្ទាប់មកបានទៅចូលរួមជាមួយបាតុករនៅមុខសណ្ឋាគារខាំបូឌីយ៉ាណា ។ គាត់ត្រូវបានបាញ់ពីក្រោយចំក្បាលផ្នែកខាងលើ ហើយបន្ទាប់មក តាមសេចក្តីរាយការណ៍ថាគាត់ត្រូវបានវាយនឹងស្នាយកាំភ្លើងត្រូវស្មា ខ្នង និងកញ្ចឹង ក ។ គាត់ត្រូវបានដឹកទៅកាន់មន្ទីរពេទ្យកាល់ម៉ែត តែបានស្លាប់នៅតាមផ្លូវនៅវេលាប្រមាណម៉ោង ៨ យប់ ។ កោសល្យវិច្ច័យមួយដែលត្រូវបានធ្វើឡើងតាមសំណូមពររបស់គ្រួសារគាត់ បានបញ្ជាក់ថាគាត់ត្រូវបានស្លាប់ដោយគ្រាប់កាំភ្លើង ដែលបាញ់ត្រូវចំក្បាល និងដោយការវាយដំ ។ សពរបស់គាត់ត្រូវបានប្រគល់ជូនគ្រួសារ ហើយដឹកទៅកាន់វត្តល័ង្កា នៅក្នុងយប់ថ្ងៃទី ៨ ខែកញ្ញា ដើម្បីបូជា។ អត្តសញ្ញាណរបស់ជនរងគ្រោះត្រូវបានបញ្ជាក់ដោយក្រុមគ្រួសារ ហើយអត្តសញ្ញាណប័ណ្ណត្រូវបានរកឃើញនៅក្នុងកាបូបរបស់គាត់ ។

(១)

២- នៅថ្ងៃទី ១០ ខែកញ្ញា នាវេលាប្រហែលម៉ោង ១៣:០០ តាមសាក្សីនានាបានឱ្យដឹងថា មាននគរបាល និងកងរាជអាវុធហត្ថ មួយក្រុមស្លៀកពាក់ជាស៊ីវិល បានចាប់ក្មេងជំទង់ ២ នាក់ នាំទៅកាន់ភូមិខ្វាញ ឃុំខ្វាញ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ហើយត្រូវបានសម្លាប់ដោយពុំមានការវិនិច្ឆ័យនៅទីនោះទៅ ។ ជនរងគ្រោះទាំង ២ នាក់នេះ ត្រូវបានឃើញដឹករស់ទៅកាន់កន្លែងនោះតាមរថយន្តពិចកិបមួយ ។ ពួកគេបានស្លៀកពាក់តែខោអាវក្នុងប៉ុណ្ណោះ ដៃទាំង ២



#18, Street 400
Sangkat Boeung Keng Kang I
Khan Chamcar Mon
Phnom Penh, Cambodia
Mailing Address: P.O. Box 108
Phnom Penh, Cambodia

Tel : (855-23) 362 585/797
Fax : (855-23) 720 030
E-mail : hchr@uni.fi

Director's Office : (855-12) 818 274, (855-15) 833 302/913 445/837 401
Administration : (855-12) 812 262
Legal Assistance : (855-15) 918 274/831 615
Education, Training & Information : (855-15) 918 273/915 096
NGOs & Reporting Obligations : (855-15) 913 447, (+12) 812 433

ចងទៅក្រោយ ។ ថ្ងៃបន្ទាប់មក សាកសពទាំង ២ នេះ ត្រូវបានរកឃើញនៅនឹងកន្លែងសម្លាប់ ដោយកប់ក្នុងផ្នូររាក់ ១ ។ សាកសពមួយត្រូវបានស្គាល់អត្តសញ្ញាណថាជាឈ្មោះ សាត សុភ័ក្រ្តា ភេទប្រុស អាយុ ១៩ ឆ្នាំ ជាសិស្សវិទ្យាល័យបាក់ទូក ។ សាកសពរបស់គេមានស្នៀកពាក់តែខោអាវក្នុងប៉ុណ្ណោះ ។ លើខ្លួនរបស់គេមានស្នាមជាំមួយយ៉ាងធំ ទំហំ ១០ សង្ទីម៉ែត្រ ត្រង់ត្រគាកខាងឆ្វេង មានរន្ធគ្រាប់កាំភ្លើងមួយគ្រាប់នៅត្រគាកខាងស្តាំ និងមួយគ្រាប់ទៀតនៅត្រង់ក្រលៀន មានស្នាមរបួសនៅលើក្បាលផ្នែកខាងក្រោយប្រហែលជាដោយគ្រាប់កាំភ្លើង ។ លលាដ៏របស់គេត្រូវបែកខ្ទេច។ ភស្តុតាងនានាដែលប្រមូលបានដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបង្ហាញថា ឈ្មោះ សាត សុភ័ក្រ្តា នេះ ប្រហែលជាបានចូលរួមធ្វើបាតុកម្មនាព្រឹកនៃថ្ងៃដែលខ្លួនគេត្រូវសម្លាប់នោះ ។ សាកសពរបស់មនុស្សទី ២ ត្រូវធ្លុះធ្លាយដោយគ្រាប់កាំភ្លើងប្រមាណចំនួន ២០ គ្រាប់ ក្នុងនេះ ៩ គ្រាប់ត្រូវបានបាញ់ទៅលើមុខ ធ្វើឱ្យការសំគាល់អត្តសញ្ញាណមានការលំបាក ។ សាក្សីនានាបានថ្លែងថា សាកសពនេះបានស្លាប់នៅនឹងកន្លែងតែម្តង ។ គាត់បានងើបខ្លួនឡើងវិញម្តងដែរនៅពេលគេបាញ់នោះ បានវារចេញពីស្នាមភ្លោះដែលគេបានដួលធ្លាក់ទៅក្នុងនោះ ហើយស្រែកឱ្យគេជួយ ។ ពួកកងរាជអាវុធហត្ថខ័ណ្ឌ ដែលបានបាញ់រូបគេនោះ ត្រូវបានអ្នកភូមិប្រាប់ថាគេនៅរស់នៅឡើយទេ ។ ពួកកងរាជអាវុធហត្ថទាំងនេះបានត្រឡប់ទៅកាន់កន្លែងនោះវិញ ហើយបាញ់ឱ្យស្លាប់ តែម្តងទៅ ។ សាក្សីបាននិយាយថាពួកគេនៅតែបាញ់ថែមទៀត នៅពេលដែលជនរងគ្រោះបានស្លាប់ទៅហើយ ។ សាក្សីបាននិយាយផងដែរថា ពួកកងរាជអាវុធហត្ថបានចេទថាជនរងគ្រោះទាំង ២ នាក់នេះមានជាប់ពាក់ព័ន្ធក្នុងការប្លន់ម៉ូតូមួយគ្រឿង ។ ពួកគេបានថតម៉ូតូដែលពួកគេបានយកទៅជាមួយដោយដាក់ម៉ូតូនោះនៅក្បែរខ្លួនសាកសព ហាក់ដូចជាដើម្បីប្រឌិតថាជាភស្តុតាង ។ រហូតមកទល់ពេលនេះ ពុំមានភស្តុតាងណាដែលបញ្ជាក់អំពីការចោទប្រកាន់ពីអំពើប្លន់នេះទេ ។

(២-៣)

៣- សាក្សីជាច្រើននាក់ដែលបានសម្ភាសន៍ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ បានឃើញសាកសពមនុស្សជំទង់ម្នាក់អាយុប្រមាណ ២០ ឆ្នាំ អណ្តែតក្នុងទឹកទន្លេសាប ម្តុំភូមិដូង ឃុំព្រែកក្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ៩ ខែកញ្ញា នៅវេលាប្រហែលម៉ោង ៥ រសៀល ។ សាកសពនេះស្លៀកខោក្នុងម៉ាក "លីអូ" ។ ដៃទាំងពីររបស់គេត្រូវបានចងទៅក្រោយភ្ជាប់ទៅនឹងឈើមានសញ្ញាខ្វែងជើងក្អែក ។ នៅលើ ក មានស្នាមច្របាច់រឹតរូត ។ សាក្សីបានរៀបរាប់ថារូបគាត់មានរូបរាង "ស្អាតបាត" សម្បុរ "សជ្រះ" ដូច "កូនចិន" កាត់សក់ខ្លី ។ សាកសពនេះទើបចាប់ផ្តើមហើម បង្ហាញថាការស្លាប់នេះអាចបានកើតឡើងរវាង ២ ថ្ងៃមុននេះប៉ុណ្ណោះ ។ អ្នករស់នៅជិត ១ ទីនោះ មិនអាចសំគាល់ពិនភាគសាកសពនេះបានទេ ហើយពុំមាននរណាម្នាក់រស់នៅទីនោះបានប្រកាសអំពីការបាត់បងប្អូនរបស់គេណាម្នាក់ក៏ទេដែរ ។ សាកសពនេះត្រូវបានទុកឱ្យអណ្តែតទៅតាមទឹកហូរទៅក្រោមបាត់ទៅ ។

(៤)

៤- អ្នកភូមិជាច្រើននាក់ ដែលត្រូវបានសម្ភាសន៍ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្សប្រចាំកម្ពុជា បានឃើញសាកសពមនុស្សចំនួន ៣ នាក់ អណ្តែតក្នុងទឹកទន្លេសាប នៅជិតភូមិព្រែកអណ្តែត ស្រុកពញាឮ ខេត្តកណ្តាល ។ សាកសពចំនួន២ ក្នុងចំណោមសាកសពទាំង ៣ នេះ ដែលត្រូវបានឃើញនៅព្រឹកថ្ងៃទី ១០ ខែកញ្ញា ត្រូវបានរៀបរាប់ថាជាសាកសពមនុស្សស្រីក្មេងម្នាក់ អាយុប្រហែលជិត ២០ ឆ្នាំ ស្លៀកពាក់ខោអាវក្នុង ។ សាកសព ២ ទៀតត្រូវបានឃើញអណ្តែតនៅឆ្ងាយពីគ្នា ពីសាកសពទី ១ នេះ ។ ដៃទាំង ២ របស់ពួកគេត្រូវចង ។ ប្រភពមួយបាននិយាយថានៅលើមុខរបស់ពួកគេមានស្នាមជាំខ្មៅ ។ ប្រភពមួយទៀតបាននិយាយថាក្បាលរបស់ពួកគេត្រូវបានវាយបែកខ្ទេចដោយវត្ថុរឹងអ្វីម្យ៉ាង ។ ប្រភពទី ៣ បានបញ្ជាក់ថានៅលើមុខមានស្នាមរបួស ។ សាកសពទី ៣ គឺជាមនុស្សប្រុសម្នាក់អាយុប្រមាណ ២០ ឆ្នាំ ។ សាកសពនេះត្រូវបានឃើញនៅថ្ងៃទី ៩ ខែកញ្ញា កើលនៅនឹងច្រាំងទន្លេ។ ដៃទាំង ២ ចងទៅក្រោយ ។ ក របស់គេមានស្នាមជាំខ្មៅ ដែលអាចបណ្តាលមកពីការរឹតរួត ។ គេមានស្នាមគ្រាប់កាំភ្លើងមួយគ្រាប់នៅលើខ្នងខាងឆ្វេង ។ សាកសពនេះត្រូវបានអ្នករស់នៅជិតខាងនោះរុញច្រានទៅក្នុងទន្លេវិញជាច្រើនលើកច្រើនសារ ។ សាកសពទាំង ៣ នេះមិនអាចត្រូវបានស្គាល់អត្តសញ្ញាណទេ ។ នៅក្នុងតំបន់នេះ គ្មានអ្នកណានិយាយថាមានបាត់សាច់ញាតិរបស់គេទេ ។ សាកសពទាំងនេះត្រូវបានហូរអណ្តែតទៅតាមចរន្តទឹកចុះទៅក្រោមបាត់អស់ ។ តាមសំដីអ្នកភូមិ នេះគឺជាលើកទី ១ ហើយដែលពួកគេបានឃើញមានសាកសពអណ្តែតនៅទីនេះ ។
(៥-៦-៧)

៥- នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩៨ វេលាប្រមាណម៉ោង ៦ ល្ងាច សាកសពមួយត្រូវបានអ្នករស់នៅតាមទូកម្នាក់ឃើញអណ្តែតក្នុងទន្លេបាសាក់នៅជិតកាស៊ីណូណាហ្គា ។ ក្នុងសម្ភាសន៍ជាមួយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សាក្សីនេះបានថ្លែងថាសាកសពនេះស្ថិតក្នុងសំលៀកបំពាក់ជាស្បង់ចីវររបស់លោកសង្ឃ ។ សាកសេពនេះត្រូវបានអណ្តែតទៅតាមចរន្តទឹកហូរបាត់ទៅ ។
(៨)

៦- នៅថ្ងៃទី ១១ ខែកញ្ញា វេលាប្រមាណម៉ោង ៩ ព្រឹក នៅកាច់ជ្រុងផ្លូវលេខ ២៤០ និងមហាវិថីព្រះមុនីវង្សមានបាតុករម្នាក់ត្រូវបានបាញ់សម្លាប់ ប្រហែលជាដោយប៉ូលិសសន្តិសុខ ។ ជនរងគ្រោះហាក់ដូចជាត្រូវបាញ់ក្នុងរយៈចម្ងាយជិត ហើយត្រូវចំខ្នងផ្នែកខាងលើ ។ ជនរងគ្រោះត្រូវបានដឹកទៅកាន់មន្ទីរពេទ្យព្រះកុសមៈ ដោយរថយន្តអង្គការសហប្រជាជាតិ ហើយត្រូវបានស្លាប់នៅពេលភ្លាម ១ បន្ទាប់មក ។ ជនរងគ្រោះត្រូវបានស័គាល់អត្តសញ្ញាណដោយសាច់ញាតិរបស់គេនៅថ្ងៃដដែលនោះថាជាឈ្មោះ ជុំ សំណាង ជាគ្រូបង្រៀនអាយុ ២៨ ឆ្នាំ មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង និងមានកូន ២ នាក់ សព្វថ្ងៃរស់នៅក្នុងទីក្រុងភ្នំពេញ ។ រូបថតរបស់ជនរងគ្រោះនៅពេលប៉ូលិសពេទ្យកំពុងព្យាយាម

ធ្វើឱ្យបានដឹងខ្លួនឡើងវិញដោយមិនបានជោគជ័យ ហើយដែលបន្ទាប់មកត្រូវបានបញ្ជាក់ថាបានស្លាប់ទៅហើយនោះ អាច រកបានទៅការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។

(៥)

៧- សាកសពចំនួន ៣ ត្រូវបានអ្នកភូមិជាច្រើននាក់ឃើញអណ្តែតក្នុងទឹកទន្លេបាសាក់កាលពីថ្ងៃទី ១១ ខែ កញ្ញា ក្នុងស្រុកស្អាង ទល់មុខទីរួមស្រុកស្អាង ខេត្តកណ្តាល ដំបូងនៅជិតភូមិកោះគោ (នាប្រហែលម៉ោង ៧ ព្រឹក) និងបន្ទាប់មកនៅជិតផ្សារវត្តជុំល្បើប (នាប្រហែលម៉ោង ៨ ព្រឹក) ។ សាកសពចំនួន ៣ ទៀត ដែលអាចជាសាកសពដដែលនោះដែរ ត្រូវបានឃើញនាព្រឹកថ្ងៃបន្ទាប់មក (ពោលគឺថ្ងៃទី ១២ ខែកញ្ញា) នៅចម្ងាយប្រមាណ ១០ គីឡូម៉ែត្រចុះទៅក្រោមចរន្តទឹកទល់មុខទំនប់ទឹកស្អាង ។ សាកសពទាំងនេះ ត្រូវ បានអ្នកនេសាទ អ្នកលក់ដូរឥវ៉ាន់នៅកន្លែងនោះ និងអ្នករត់ទូកដរ បានឃើញ ។ សាកសពមួយ ក្នុងចំណោម សាកកសព ៣ នេះ ដែលត្រូវបានអ្នកភូមិឃើញនៅវេលាប្រហែលម៉ោង ៩ ព្រឹក ត្រូវបានគេនិយាយថា គឺ ជាសាកសពមនុស្សស្រី ។ អ្នកភូមិបានប្រាប់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្សប្រចាំកម្ពុជានៅថ្ងៃទី ១៣ ខែកញ្ញានេះថា សាកសពនេះបានអណ្តែតទៅចម្ងាយជាច្រើនគីឡូម៉ែត្រ ចុះក្រោមចរន្តទឹក ឆ្ពោះទៅកាន់ព្រែកយួហេង។ នៅថ្ងៃទី ១៧ ខែកញ្ញា អ្នកភូមិនៅមាត់ព្រែក ក្នុងឃុំ ត្រើយស្លា ភូមិ ៣ បានបញ្ជាក់ថាពួកគេបានឃើញសាកសពចំនួន ៣ កាលពីថ្ងៃទី ១២ ខែកញ្ញា ។ ពួកគេបាននិយាយថាសាកសពចំនួន ២ បានហូរទៅតាមចរន្តទឹកទៅបាត់ហើយ ។ ពួកគេបានរៀបរាប់ថា សាកសពទាំងនោះសុទ្ធតែត្រូវចងដៃទៅក្រោយទាំងអស់ ។ សាកសពទី ៣ គឺជាស្ត្រី ។ ពួកគេបានបញ្ជាក់ថា សាកសពនេះបានអណ្តែតចូលទៅក្នុងប្រឡាយទឹកនៅថ្ងៃជាមួយគ្នា ហើយត្រូវបានអ្នករស់នៅទីនោះរុញច្រាន ឱ្យចូលទៅក្នុងទន្លេវិញជាច្រើនសារ ។ នៅថ្ងៃទី ១៧ ខែកញ្ញា បុគ្គលិកការិយាល័យនៃឧត្តមស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានឃើញសាកសពទៅទើនៅនឹងគុម្ពត្រែងក្នុងបឹង ឡាថេង ស្ថិតនៅចម្ងាយ ៤ គីឡូម៉ែត្រពីទីនោះ នៅចុងប្រឡាយ ។ សាកសពនេះពិតជាសាកសពស្ត្រីមែន ស្លៀកខោពណ៌ខ្មៅ ពាក់អាវយឺតដៃខ្លីពណ៌សនៅផ្នែកខាងលើដងខ្លួន និងអាវយឺតពណ៌ក្រហមចំហទ្រូងពីលើ។ សាកសពនេះស្ថិតក្នុងភាពរលេះរលួយខ្លាំងណាស់ទៅហើយ មានដង្កូវចោះលើមុខ ពោះហើមយ៉ាងខ្លាំង និង ស្បែកឡើងជាំ ។ សពនេះសន្ធឹងខ្លួនដោយផ្កាប់មុខទៅក្រោម ដៃសន្ធឹងទៅក្រៅ មិនអាចសំគាល់ភិនភាគបាន ទេ ។ រូបថតមួយចំនួន ត្រូវការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជាថតយកបាន ។

(១០-១១-១២)

៨- នៅថ្ងៃទី ១១ ខែកញ្ញា វេលាប្រមាណម៉ោង ៦ ព្រឹក នៅក្នុងឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល សាក្សីជាច្រើននាក់ដែលការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានជួបសម្ភាសន៍ បានឃើញសាកសពមួយអណ្តែតក្នុងទឹកនៅមុខមន្ទីរពេទ្យស្រុក ។ ដៃរបស់សពនេះត្រូវបានចងទៅក្រោយ ។ ពុំមានព័ត៌មានពិស្តារជាងនេះត្រូវបានផ្តល់ឱ្យទេ ដោយសារសពនេះស្ថិតនៅឆ្ងាយពីច្រាំងពេក ។ ថ្ងៃបន្ទាប់មក វេលាប្រហែលម៉ោង ៦ ព្រឹក នៅកន្លែងដដែលនេះដែរ មានសាកសពមួយទៀតត្រូវបានឃើញកំពុងអណ្តែតចុះទៅក្រោមខ្សែទឹកទន្លេ ដោយដៃចងទៅក្រោយដែរ ។

(១៣-១៤)

៩- អ្នកភូមិជាច្រើននាក់ ដែលត្រូវបានសម្ភាសន៍ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ១៩៩៨ បានរាយការណ៍ថា ពួកគេបានឃើញសាកសពមនុស្ស ៣ នាក់ អណ្តែតចេញពីទំនប់ទឹកថ្លា នៃស្ទឹងព្រែកត្នោត នៅក្នុងឃុំក្រាំងពង្រ ស្រុកដង្កោរាជធានីភ្នំពេញ ។ សាកសពទាំងនេះ ត្រូវបានឃើញអណ្តែតនៅកណ្តាលលំហទឹកដ៏ទូលំទូលាយរបស់ទំនប់ដែលគ្របដណ្តប់ទៅដោយដើមឈូក ឆ្ងាយពីផ្លូវជាតិលេខ ៣ ។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានទៅពិនិត្យមើលទីនេះជាលើកទី ២ ម្តងទៀត នៅថ្ងៃទី ១៤ ខែកញ្ញា ដើម្បីរកមើលសាកសពទាំងនេះ តែរកមិនឃើញ បានឃើញសាកសពមួយផ្សេងទៀត នៅផ្នែកខាងក្រោមទំនប់ (សូមមើលករណីទី ១៣ ខាងក្រោមនេះ)

(១៥-១៦-១៧)

១០- សាកសពមនុស្សប្រុសម្នាក់ អាយុប្រហែលជិត ៤០ ឆ្នាំ ឬលើស ៤០ឆ្នាំបន្តិច ត្រូវបានការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ចុះទៅពិនិត្យនៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ១៩៩៨ នៅ គីឡូម៉ែត្រទី ១៩ នៃផ្លូវជាតិលេខ ២ ក្នុងភូមិស្រីស្នំ ឃុំកំពិស ស្រុកកណ្តាលស្ទឹង ចម្ងាយប្រមាណ ២០០ ម៉ែត្រខាងនាយស្ពានដែក នៅក្នុងប្រឡាយទឹកសំរាប់ស្រោចស្រពស្រែមួយ ។ នៅព្រឹកថ្ងៃជាមួយគ្នានោះដែរ នគរបាលមូលដ្ឋានកន្លែងនោះក៏បានចុះទៅរកមើលសាកសពនេះដែរ តែមិនបានធ្វើការពិនិត្យអ្វីទេ ។ ក្រោយមក សាកសពនេះ ត្រូវបានពិនិត្យដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ

មនុស្សប្រចាំកម្ពុជា ។ សាកសពមានស្បែកជាំខ្មៅរលៈ មាឌខ្ពស់ ( ប្រហែល ១.៨០ ម៉ែត្រ) ចងមុខ ដៃចង ទៅក្រោយដោយខ្សែភ្លើង ដូចជាមិនឃើញមានស្នាមរបួសដោយគ្រាប់កាំភ្លើងទេ មានឈាមនៅក្នុងមាត់ មានស្នាមខ្មៅជាំនៅជុំវិញក ដែលអាចបណ្តាលមកពីការរឹតរូត ។ ក្រម៉ាពណ៌ក្រហមលាយសមួយ ត្រូវបាន ញ៉ុកក្នុងមាត់ ។ មនុស្សនេះពាក់អាវខូវប៊យពណ៌ត្នោត ដែលជាអាវដៃវែងឆ្នូតពណ៌ត្នោតលាយស ស្លៀកខោ ខ្លីមានហោប៉ៅសងខាង និងខោស្លីបម៉ូតបច្ចឹមប្រទេសមួយ ។ សាកសពមានខ្សែចង្កេះមួយខ្សែ ។ ជនរង គ្រោះមិនអាចសំគាល់អត្តសញ្ញាណបានទេ ។ សាកសពនេះត្រូវហើម បន្ទាប់ពីត្រាំក្នុងទឹកប្រហែលជាច្រើនថ្ងៃ មកហើយនោះ ។ រូបថតត្រូវបានថតយកបានដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នៅពេលមុន និងក្រោយធ្វើការពិនិត្យ ។

(១៨)

១១- នៅថ្ងៃទី ១៤ ខែកញ្ញា វេលាប្រមាណម៉ោង ៧ ព្រឹក នៅភូមិតាស្ទួ ឃុំសារិកាកែវ ស្រុកល្វាឯម អ្នកភូមិជាច្រើននាក់បាននាំគ្នាទៅមើលសាកសពអណ្តែតទឹកមួយ នៅក្បែរច្រាំងទន្លេ ។ សាកសពមានស្នាម គ្រាប់កាំភ្លើងមួយគ្រាប់នៅក្បែរកញ្ចឹងក និងស្នាមរយះនៅលើស្មា ។ កត្រូវអារដាច់ពាក់កណ្តាល ។ សាក សពស្លៀកខោខ្លីពណ៌ខៀវ ។ អ្នកភូមិបានរុញសាកសពនេះឱ្យអណ្តែតទៅតាមចរន្តទឹក (ពាមឧកញ៉ាអុង កោះរាលើ កោះរាក្រោម) មុននឹងត្រូវបានយកចេញទៅដោយកាណូតរបស់នគរបាលខេត្តកណ្តាល បើតាម អ្នកបានឃើញ ។

(១៩)

១២- សាកសពមនុស្សប្រុសម្នាក់ អាយុប្រហែលជិត ៣០ ឆ្នាំ ត្រូវបានពិនិត្យដោយបុគ្គលិកការិយាល័យនៃ ឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នារសៀលថ្ងៃទី ១៤ ខែកញ្ញា នៅ ក្នុងភូមិអង់ ឃុំប្រទះឡាង ស្រុកដង្កោ រាជធានីភ្នំពេញ ។ សាកសពនេះស្ថិតនៅក្នុងទឹកក្បែរមាត់ច្រាំងស្ទឹង ព្រែកត្នោត ។ សាកសពមានកកំពស់ប្រហែល ១.៦៥ ម៉ែត្រ ដៃទាំង ២ ចងទៅក្រោយដោយខ្សែអង្រឹង ។ ខ្សែគោមួយដុំត្រូវបានឃើញស្ថិតនៅជុំវិញកសាកសព ។ មានស្នាមរបួសដោយគ្រាប់កាំភ្លើងនៅទ្រូងផ្នែកខាង ស្តាំជិតដោះ និងស្នាមគ្រាប់ចេញមួយគ្រាប់នៅលើខ្នង ។ មានស្នាមរបួសចំហមួយផងដែរនៅផ្នែកខាងមុខ នៃក ។ ពោះត្រូវធ្លាយ ពោះវៀនចេញមកក្រៅ ។ មុខហើមស្អុល និងរលួយអស់មួយចំណែកហើយ ។

សាកសពស្លៀកតែខោខ្លីធម្មតា ពណ៌បៃតងមួយប៉ុណ្ណោះ ។ សាកសពមានខ្សែចង្កេះមួយនៅជុំវិញចង្កេះ ។ សាកសពមិនត្រូវបានគេប្រកាសឱ្យដឹង និងអាចសំគាល់អត្តសញ្ញាណបានទេ ។ សាកសពនេះដូចគ្នានឹងភិនភាគ នៃសាកសពមួយទៀត ដែលត្រូវបានបូជាកាលពី ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៩៨ វេលាម៉ោងប្រមាណ ១០ កន្លះព្រឹក នៅមាត់ទន្លេក្បែរវត្តទឹកថ្លា ។ អ្នកភូមិដែលបានបូជាសពនោះ បានសង្កេតឃើញមានចាក់សាក់រូបផ្កាឈូក នៅលើស្មាខាងឆ្វេង ។ រូបថតសាកសព និងការបូជាសព ត្រូវបានថតយកបាន ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។

(២០)

១៣- សាក្សីបានឃើញផ្ទាល់ភ្នែកម្នាក់ ដែលបានសម្ភាសន៍ដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នៅកន្លែងឆ្លងដរព្រែកឯង ក្នុងស្រុកគៀនស្វាយ ខេត្តកណ្តាល បានថ្លែងថា កាលពីថ្ងៃទី ១៥ ខែកញ្ញា វេលាប្រមាណម៉ោង ៤ រសៀល គាត់បានឃើញសាកសពមនុស្ស ៣ នាក់អណ្តែតតាមដងទន្លេមេគង្គ នៅចម្ងាយប្រហែល ២០ ម៉ែត្រពីច្រាំង ស្ថិតនៅទល់មុខភូមិតាស្ទួ ឃុំសារិកាកែវ ។ សាកសព ២ ស្លៀកពាក់ជាស៊ីវិល ហើយអ្នកទី ៣ ពាក់ស្បង់ចីវរលោកសង្ឃ ។ សាកសពទាំង ៣ សុទ្ធតែត្រូវចងដៃទាំង ២ ទៅក្រោយ ។

(២១-២២-២៣)

១៤- សាកសពមនុស្សម្នាក់ ត្រូវបានការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជារកឃើញកាលពីថ្ងៃទី ១៦ ខែកញ្ញា នៅមាត់ទន្លេមេគង្គជិតកោះពស់ ក្នុងឃុំដីឥដ្ឋ ស្រុកគៀនស្វាយ ។ លលាដ៏ក្បាលត្រូវបែកខ្ទេចជាបំណែកតូច ១ ហើយដៃទាំង ២ ត្រូវចងទៅក្រោយដោយខ្សែនីឡុង ។ ក្រម៉ាមួយ ត្រូវបានចងនៅជុំវិញក ។ សាកសពស្ថិតក្នុងភាពរលួយរលេះខ្លាំងណាស់ទៅហើយ ដោយសាច់ និងស្បែកមួយផ្នែក ត្រូវបានក្រៀមដោយកំដៅថ្ងៃ ។ ដោយហេតុនេះ ភេទរបស់សាកសពមិនអាចកំណត់បានទេ ។ រូបថតត្រូវបាន ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាថតយកបាន ។

(២៤)

១៥- សាកសពមនុស្សប្រុសម្នាក់ត្រូវបានឃើញកាលពីថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ១៩៩៨ នៅក្នុងស្ទឹងព្រែកត្នោត ភូមិអង់ ឃុំប្រទះឡាង ស្រុកដង្កោ រាជធានីភ្នំពេញ (នេះគឺជាទីកន្លែងដដែល ដែលសាកសពមួយត្រូវបានឃើញ កាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ១៩៩៨ ហើយដែលត្រូវបានបូជានៅថ្ងៃទី ១៦ ខែកញ្ញា - សូមមើលករណីទី ១៣ ខាងលើនេះ) ។ សាកសពនេះត្រូវបានអណ្តែតផ្កាប់មុខ ខ្លួនអាក្រាត ជើងដាច់ចេញដោយឡែក នៅចន្លោះខាងក្រោមនៃទំនប់ ។ ដៃត្រូវចងត្រង់កំភួនដៃទៅក្រោយដោយអាវយឺតសាច់អម្បោះ។ មានខ្សែអង្រឹងនៅព័ទ្ធជុំវិញករបស់សាកសព ។ ដៃឆ្វេងត្រូវបាក់ចំពាក់កណ្តាលដៃ ។ ដៃស្តាំត្រូវបាក់នៅត្រង់កដៃ ។ ពុំមានស្នាមរបួសដោយគ្រាប់កាំភ្លើងនៅលើខ្លួនទេ ។ កហាក់ដូចជាត្រូវបាក់ ហើយឆ្អឹងក្បាលភាគច្រើនត្រូវបាត់ ដោយសារថាក្បាលត្រូវបានបែកខ្ទេច ។ ដើមទ្រូងផ្នែកខាងមុខ និងពោះ ដែលបានលិចចូលទៅក្នុងទឹកត្រូវបានខូចខាតស្ទើរអស់ (ត្រូវរលេះរលួយ និងត្រូវត្រីស៊ី) ។ នគរបាលមូលដ្ឋាន និងនគរបាលរាជធានីភ្នំពេញ បានមកពិនិត្យសាកសពនេះ នៅក្នុងថ្ងៃជាមួយគ្នានេះដែរ (១៨ កញ្ញា) ។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានថតរូបភាពរបស់សាកសពនេះ ។

(២៥)

១៦- ឈ្មោះ ជ័យ ឧត្តម (ហៅ អាចិន) អាយុ ២៩ ឆ្នាំ ត្រូវបានមនុស្សមិនស្គាល់អត្តសញ្ញាណ ២ នាក់ស្លៀកពាក់ស៊ីវិលបាញ់សម្លាប់ នៅវេលាប្រហែលម៉ោង ៧កន្លះ ល្ងាចថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៩៨ តាមផ្លូវលេខ ១៥០ ក្នុងរាជធានីភ្នំពេញ ។ នៅពេលជនរងគ្រោះបានចាកចេញពីផ្ទះសាច់ញាតិម្នាក់ដោយម៉ូតូ មានជនមិនស្គាល់អត្ត សញ្ញាណ ២ នាក់ ដែលហាក់ដូចជាបានរង់ចាំរូបគេនោះ បានជិះម៉ូតូតាមពីក្រោយ ហើយបានបាញ់រូបគេពីក្រោយក្នុងរយៈចម្ងាយយ៉ាងជិត ចំក្បាល ។ គ្រាប់កាំភ្លើងបានត្រូវចំថ្ពាល់ខាងឆ្វេង រួចធ្លាយចេញតាមផ្នែកខាងក្រោយក្បាល បានសម្លាប់រូបគេស្ទើរតែនៅនឹងកន្លែងតែម្តង ។ ការរកឃើញជាបឋមបង្ហាញថាជនរងគ្រោះធ្លាប់ធ្វើការជាអង្គរក្សរបស់សមាជិកសភាគណបក្សហ៊្វុនស៊ិនប៉ិចមណ្ឌលខេត្តកណ្តាល ។ រូបគេក៏ធ្លាប់បានធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោតសំរាប់គណបក្សនេះដែរ ក្នុងពេលបោះឆ្នោតនាខែកក្កដាកន្លងទៅនេះ ។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាក៏បានធ្វើការផ្ទៀងផ្ទាត់អំពីការចោទប្រកាន់ដែលថាជនរូបនេះបានចូលរួមបាតុកម្មយ៉ាងសកម្មនោះដែរ ។ នគរបាលខ័ណ្ឌទួលគក បានពិនិត្យសាកសពនេះភ្លាម ១ បន្ទាប់ពីឃាតកម្មបានកើតមានឡើង ។ នៅយប់នៃថ្ងៃដដែលនោះ សាច់ញាតិជនរងគ្រោះបានយកសាកសពរបស់គេទៅវត្តព្រះពុទ្ធដើម្បីបូជា ។ រូបថតជនរង

គ្រោះ ភ្លាម ៗ បន្ទាប់ពីឃាតកម្ម ត្រូវការិយាល័យនៃឧត្តមស្នងការអង្គការសហ ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាថតបាន ។
(២៦)

ភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៨

ការបកប្រែសំរួលពីអត្ថបទដើមជាភាសាអង់គ្លេស